
រៀបរៀងចងក្រង
ស៊ូ.ចំរើន
ឯកសារ
ប្រវត្តិសាស្ត្រ
ពោធិ៍កំបោរ
ប្រវត្តិតស៊ូនៃវីរបុរសខ្មែរ ក្នុងសតវត្សទី ១៩

# អារម្ភកថា

គឺជាការពិតណាស់ មិត្តអ្នកនិពន្ធខ្មែរទាំងអស់ក្នុងសម័យសាធារណរដ្ឋ កំពុងតែពួតដៃគ្នាយ៉ាងជិតស្និទ្ធ ស្ថាបនាថ្នាលអក្សរសាស្ត្រជាថ្មី ដើម្បីបណ្តុះពូជធារវប្បធម៌ខ្មែរ ឲ្យដុះដាលវាលគុម្ពធំធេងដូចអារ្យប្រទេសនានា ។

យើងបានកន្លងផុតរបបរាជានិយមចាស់គម្រិល ដែលចុកមាត់មិនឲ្យបញ្ចេញការពិត ជាទំនាស់រាជបល្ល័ង្កដ៏អាស្រូវ ។

ឥឡូវនេះ កូនខ្មែរដណ្តើមយកបានសេរីភាពពេញបរិបូណ៌ហើយ ដូច្នេះបើឃើញប្រច័ក្ខ ឬច្បាស់នឹងត្រចៀក យល់ប្រាកដប្រជាក្នុងចិត្តយ៉ាងណា ត្រូវតែហ៊ាននិយាយយ៉ាងនោះភ្លាម កុំបីនៅអល់អែកឡើយ ។

អាស្រ័យហេតុនេះហើយ ទើបខ្ញុំបានខិតខំស្រាវជ្រាវរាវរកធាតុពិតនៃវីរបុរសខ្មែរ តាមរយៈឯកសារជាតិនិងបរទេស ពាក្យដំណាលរបស់ចាស់ទុំយកមកពូតផ្សំបញ្ចូលគ្នា កកើតបានរូបរាង «អាចារ្យស្វា» ក៏ដូច «ពោធិកំបោរ» ដែរ ។

សូមឲ្យរឿង «ពោធិកំបោរ» នេះ រស់រវើកឡើងវិញ សមតាមការចង់ចេះដឹងរបស់មិត្តអ្នកអានគ្រប់ប្រភេទ ។

**ស៊ូ~ចំរើន**

# អាចារ្យស្វា ពោធិកំបោរ

តាំងពីដឹងក្តីមក ខ្ញុំបាទតែងឮចាស់ទុំប្រាប់ឮដល់នាម អាចារ្យស្វា ពោធិកំបោរ ភ្ជាប់គ្នា ដែលនាំឲ្យយល់ថា ឈ្មោះវីរបុរសតែម្នាក់ ឬពីរនាក់ ជាកល្យាណមិត្តនឹងគ្នាក៏មិនដឹង ?

ឯការពិតតាមឯកសារវិញ ពុំមែនដូច្នោះទេ ថ្វីដ្បិតតែវរជនទាំងពីរធ្វើការបដិវត្តន៍ ក្នុងសតវត្សរ៍ទី១៩ដូចគ្នាក៏ដោយ ក៏អាចារ្យស្វា បានផ្តួចផ្តើមមុន ពោលគឺប្រឆាំងជាមួយអាណានិគមនិយមបារាំងសែស និងរបបស្តេចផ្តាច់ការ លុះត្រាអវសានជីវិតក្នុងខែសីហា គ.ស.១៨៦៥ ។

រំលងមួយឆ្នាំក្រោយមក គ.ស.១៨៦៦ ទើបពោធិកំបោរងើបឡើងប្រយុទ្ធតស៊ូនឹងទ័ពហ្លួង-បារាំង ក្នុងរយៈពេលប៉ុន្មានខែប៉ុណ្ណោះ លោកដណ្តើមយកបាននគរកម្ពុជាធិបតីទាំងមូល លើកលែងតែឧដុង្គនិងភ្នំពេញ ទីក្រុងកាន់កាប់ដោយទ័ពបារាំងសែស (១) ។

ទម្លាប់ហៅ អាចារ្យស្វា-ពោធិកំបោរ រត់មាត់ដូច្នេះ ពិតជាសមហេតុផលណាស់ ព្រោះបុព្វវីរបុរសយើងទាំងពីររូបនេះ សឹងមានឧត្តមគតិដូចគ្នាបេះបិទឥតល្អៀង គួរគប្បីរំឭកនាមអាចារ្យស្វា-ពោធិកំបោរ បែបនេះតទៅទៀត ដើម្បីឲ្យស្រួលមាត់ និងជៀសវាងការភ្លេចភ្លាំងផង ។

ខ្ញុំបាទមានកិត្តិយស សូមលើកទំព័រប្រវត្តិសាស្ត្រតស៊ូរបស់ពោធិកំបោរ ដើម្បីបានជាប្រទីបតូចមួយ សំរាប់ទ្រោលបំភ្លឺឲ្យឃើញនូវវីរភាពដ៏ខ្ពង់ខ្ពស់ គួរគោរពនិងប្រកាន់យកទុកជាទិដ្ឋានុគតិតទៅ ។

---

១- Le Cambodge III page 303 par E. Aymonier.

# ~១~

# បុរសឈ្មោះបឺ

នៅក្នុងស្រុកកំពង់ស្វាយទាំងមូល នរណាក៏ទទួលស្គាល់គ្រូពៅដែរ ព្រោះគាត់មានចំណេះដឹងខាងមន្តអាគមគាថានិងផ្សំថ្នាំសង្កូវ កែរោគាព្យាធិផ្សេងៗយ៉ាងពូកែសក្តិសិទ្ធិថែមទៀតផង ។

ពេលកើតរោគតម្កាត់ ឬមួយមានអាសន្នអន់ក្រ ដែលបណ្តាលមកពីខ្មោចព្រាយបិសាច អារក្សអ្នកតាធ្វើទុក្ខបុកម្នេញ បងប្អូនញាតិកានៃអ្នកជម្ងឺតែតតែទៅអញ្ជើញគ្រូពៅ មកជួយដោះឲ្យរួចរស់ជីវិតស្ទើរគ្រប់គ្នា ។ ម្ល៉េះហើយកេរ្តិ៍ឈ្មោះល្អរបស់គ្រូពៅ លេចឮសាយភាយពីមាត់មួយទៅមាត់មួយថា គួរយកជាទីពឹងពាក់ពំនាក់អាស្រ័យបានឥតទាស់ ។

ទោះបីរស់នៅស្រណុកសុខស្រួលក្នុងឋានៈជីវភាពជាគ្រូហ្នឹងដូច្នេះក៏ដោយ ក៏គ្រូពៅពុំអាចទ្រាំទល់ភ្នែកមើលស្ដេច ដែលបើកដៃឲ្យអាណានិគមនិយមបារាំងសែសត្រួតត្រាដែនដីជាកេរ្តិ៍មរតកដូនតា ដ៏មានតម្លៃលើសលែងអាយុជីវិតនេះកើតដែរ ។ ចិញ្ចឹមចិត្តស្នេហាជាតិមាតុភូមិយ៉ាងមុតមាំដូច្នេះហើយ ទើបគ្រូពៅចាំបាច់ត្រូវតែគេចចេញឲ្យឆ្ងាយពីស្រុកទេស ដែលរាជការកាន់កាប់ជាភ្នែកច្រមុះរបស់ហ្លួង ។

ដំណើរផ្សងព្រេងវែងឆ្ងាយ រហូតដល់ទៅស្រុកលើ ហាក់ធ្វើឲ្យគ្រូពៅកាន់តែមានសង្ឃឹមនឹងជីវិតទ្វេឡើងជាលំដាប់ ។ គាត់បានយកបក្សពួកជាមួយកួយ ស្មៀង និងខ្មែរយើង ដោយគ្មានរើសអើងអ្វីឡើយ ។

អាស្រ័យដោយអាកប្បកិរិយាដ៏ប្រពៃ ពោលគឺដឹងទុក្ខធុរៈគ្នាក្នុងគ្រាក្រ គ្រូពៅបានទៅជាទីពេញចិត្តនៃអ្នកទាំងឡាយពន់ពេក ។ មានខ្លះជជីកសួររកសាវតាជាតិរបស់គាត់ ដើម្បីធ្វើកំណត់កត់ចំណាំទុកក្នុងពោះ ។

- សូមទោសលោកអាចារ្យនាមអីដែរ គ្រាន់យើងខ្ញុំបានស្គាល់ទៅថ្ងៃមុខថ្ងៃក្រោយផង ?

និស្ស័យគ្រូពៅមិនសូវចង់បញ្ចេញឈ្មោះកំណើតកើតជាឲ្យគេឯងស្គាល់វាល់ដែរទេ ។ ហេតុនេះហើយ ទើបគាត់ឆ្លើយតបបែបជាប្រស្នាទៅវិញ ៖

- ខ្ញុំឈ្មោះលាក់ !

គឺបានសេចក្ដីថា គាត់លាក់ឈ្មោះពិតប្រាកដនោះទុកហើយ កុំបីសង្ស័យឡើយ ។ ផ្ទុយទៅវិញចាស់ទុំម្នាក់បែរជាកាត់យល់ ព្រមទាំងឲ្យន័យជ្រៅជ្រះ ៖

- អ្ហ៎ !... ឈ្មោះលក្ខណ៍ទេតើ នាមនេះសក្តិសមនឹងរូបអាចារ្យ ដែលមានលក្ខណៈល្អប្រសើរគ្រប់ប្រការមែន !

ចំណែកអ្នកឯទៀត ដែលនឹកថាគ្រូពៅនិយាយតាមត្រង់ ក៏ចេះនាំគ្នាហៅ ៖

- អាចារ្យលាក់ៗ !...

នាសម័យថ្ងៃមួយ មានស្រីទុរគតម្នាក់បីកូនខ្ចីនៅដៃ រត់រលះរលាំងតម្រង់មករកអាចារ្យលាក់ ដោតអាការៈភ័យតក្កមា ៖

- ជំរាបសួរលោកអាចារ្យ !

គ្រូពៅផ្ដុំហត្ថាសំដែងការគួរសមទៅវិញ ៖

- បាទ !... លើកដៃថ្វាយព្រះ ! ចុះនាងមានការអីមុខមាត់ដូចជាភ័យខ្លាំងម្ល៉េះ?

-សូមលោកអាចារ្យ អញ្ជើញទៅជួយសង្គ្រោះប្ដីខ្ញុំផង គាត់ចេះតែចុកពោះរកកលតែចង់ផុតម្ដងៗហើយ !

ពេលនោះ គ្រូពៅរាប់ដៃមើលបន្តិច ទើបឆ្លើយឡើងគួរឲ្យទុកចិត្ត ៖

- កុំបារម្ភខ្លាំងពេក ប្ដីនាងមិនអីទេ ព្រោះនាងបានមករកខ្ញុំថ្មើរណោះ ឈ្មោះថាមានដង្ហើមរស់ពិត !

កាលបើទាយបញ្ជាក់ តាមក្បួនយាមយោគយាត្រាដូច្នេះហើយ អាចារ្យលាក់យកថង់យាមពាក់លើស្មា រួចម្ដីម្ដានាំខ្លួនទៅជាមួយស្ត្រីនោះភ្លាម ។ មិនយូរប៉ុន្មានក៏ចូលដល់មុខខ្ទមជរាមួយ ដែលឮសូរសម្លេងអ្នកជម្ងឺថ្ងូរដូចព្រាប លាយឡំនឹងមាត់អ្នកស្រុកភូមិចរចាគ្នារអ៊ូៗ ទ្រង់ខ្វល់ខ្វាយអំពល់ក្នុងចិត្ត ។

គ្រាន់តែក្រឡេកឃើញ អាចារ្យលាក់ដើរតម្រង់មកចំ អ្នកទាំងឡាយត្រេកអរសាទរឥតឧបមា ៖

- ជំរាបសួរលោកអាចារ្យ សូមអញ្ជើញឡើងមក ពួកខ្ញុំខំប្រឹងរង់ចាំមើលតែផ្លូវ !

- ហ៊ឺរកកន្ទេលក្របហមក្រាលជូនលោកអាចារ្យ !

ទឹកមុខញញឹមស្រស់ស្រាយជាប់ជានិច្ច គ្រូពៅប្រញាប់រាដៃប្រកែក ៖

- បងប្អូនអើយ មិនបាច់គួរសមអីពេកទេ ខ្ញុំអង្គុយផ្ទាល់នឹងរនាបបានហើយ !

ពុំទាន់ស្រដីរួចពីមាត់ គាត់សំរុតខ្លួនចុះបត់ជើង រួចចាប់ផ្ដើមស្ទាបស្ទង់មើលអាការៈរោគរបស់អ្នកជម្ងឺ ដែលដេករមួលខ្លួនដូចអន្ទង់ ៖

- ពីមុនមកលោកប្អូនឯងដែលឈឺអញ្ចឹងទេ ?

បុរសកំសត់គ្រវីក្បាល ត្រដរឆ្លើយតបឮដាច់ៗ ៖

- ទេ !... ទើបតែម្ដងហ្នឹងគត់...

- បើអ៊ីចឹងលែងភ័យទៅ លោកប្អូនឯងនឹងបានជាសះស្បើយយ៉ាងឆាប់បំផុត

លុះផ្តល់សេចក្តីសង្ឃឹមដល់អ្នកជម្ងឺដូច្នេះហើយ គ្រូពៅនិយាយទៅកាន់ស្ត្រីមេផ្ទះ ៖

- នាងទៅដុតផ្លែចបជីកមួយឲ្យក្រហមមក !

ភរិយាអ្នកជម្ងឺទទួលពាក្យអាចារ្យលាក់ហើយ ក៏ប្រញាប់ប្រញាល់បង្កភ្លើងដុតផ្លែចប លោហធាតុត្រូវនឹងកំដៅអគ្គីឡើងក្រហមស្ទើរលោយក្លាយជាវត្ថុរាវ ។ នាងកាន់ចបជីកនោះយកទៅសួរ ៖

- ប៉ុណ្ណឹងបានទេលោកអាចារ្យ ?

- នាងដាក់ចុះមក !

ខណៈនោះ អាចារ្យលាក់លាងជើងខ្លួនគាត់ស្អាតបាតហើយ ក៏ជាន់ទៅលើផ្លែចបកំពុងពេញក្តៅឬសួរឆាវ រួចគាត់យកជើងនោះស្ទំពោះឲ្យអ្នកជម្ងឺ ៖

- បើក្តៅខ្លាំងពេក កុំភ្លេចប្រាប់ខ្ញុំណា៎ !

- បាទ... ឥឡូវ... ឧណ្ហស្រួលណាស់ !

គ្រូពៅធ្វើតាមវិធីនេះតែពីរបីដងប៉ុណ្ណោះ អ្នកជម្ងឺបានស្រាកស្រាន្តក្នុងខ្លួន រហូតដល់ទៅអង្គុយកើត ចេះទាររកបាយទឹកមួយរំពេច ។ ដោយសារអាចារ្យលាក់មានតំរេះវិជ្ជាពូកែសក្តិសិទ្ធិដូច្នេះហើយ ទើបអ្នកស្រុក-ភូមិព្រៃលើទុកចិត្តគាត់យ៉ាងមាំ

ប្រជាប្រិយភាពរបស់អាចារ្យលាក់រីកធំឡើងជាដរាប ត្រាតែគាត់អាចនិយាយបញ្ចុះបញ្ចូលបានស្មគ្រ័បក្សពួកយ៉ាងក្រាស់ក្រែល ដើម្បីកជាទ័ពលើកទៅច្បាំងនឹងទាហានបារាំងនៅបន្ទាយរោងដំរី ។ បិតចំពោះមុខកងពលសកលយោធា គាត់ថ្លែងសារទុក្ខយ៉ាងក្លៀវក្លា ៖

- បងប្អូនរួមឈាមជាទីស្នេហា ! ដូចបងប្អូនជ្រាបស្រាប់ហើយ សព្វថ្ងៃនេះប្រទេសជាតិមាតុភូមិជាទីស្នេហាស្មើនឹងអាយុជីវិតយើងរាល់គ្នា ត្រូវធ្លាក់ក្រោមការត្រួតត្រារបស់បរទេស ព្រោះតែហ្លួងចង់ផ្ញើវាសនាលើបារាំង មិនព្រមប្រគល់សេចក្តីទុកចិត្តមកប្រជារាស្ត្រសោះ ។ តើបារាំងសែសស្រឡាញ់ខ្មែរជាងខ្មែរយើងឬ ?

អាចារ្យលាក់សង្កត់កន្ទុយសំនួរនេះយ៉ាងធ្ងន់ ទ្រង់ក្តៅចិត្តឆ្អិតទ្រូងឥតឧបមា ព្រមទាំងទុកឱកាសឲ្យស្មគ្រ័បក្សពួកធ្វើការត្រិះរិះពិចារណាមួយសន្ទុះ ។ លុះស្ទង់មតិដឹងថា អ្នកទាំងឡាយបាក់ចិត្តគំនិតតាមគាត់ខ្លាំងហើយ គ្រូពៅក៏ប្រកាសថែមទៀត បែបកាន់តែច្បាស់លាស់ជាងមុនច្រើន ៖

- ដរាបណាជីវិតនៅរស់ ឈ្មោះជាកូនខ្មែរពូជសាងអង្គរវត្ត ខ្ញុំអាចារ្យលាក់ហៅពោធិកំបោរ សូមប្រឆាំងជាដាច់ខាតនឹងបរទេសឈ្លានពាន ដែលស្តេចពផែនដីបើកដៃឲ្យមកត្រួតខ្មែរទូទាំងនគរ ។ ពោធិកំបោរខ្ញុំសុខចិត្តស្លាប់ ប្រសើរជាងឱនក្បាលជ្រកក្រោមម្លប់រាជបល្ល័ង្ក មានបារាំងត្រូវត្រួតពីលើថែមមួយជាន់ទៀត ។ ប

ងប្អូនយល់យ៉ាងណា សូមអញ្ជើញបញ្ចេញយោបល់តាមការគួរចុះ !

បុរសចំណាស់ម្នាក់បានមាត់ក លើកដៃឡើងនិយាយភ្លាម ៖

– ខ្ញុំសុំគាំទ្រប្រសាសន៍លោកអាចារ្យទាំងស្រុង !

យុទ្ធជនឯទៀត ក៏បន្លឺសំរែកជយឃោសគឹកកងរំពងស្ទើររកស្តាប់ទិសតំបន់អ្វីពុំបានឡើយ ។ មានតែអ្នកសម្លេងធំទេ ដែលស្រែកឮច្បាស់ជាងគេឯង ។

– យើងត្រូវតែនាំគ្នាដើរតាមលោកអាចារ្យលាក់ !

– ជយោពោធិកំបោរ !

– បរាជ័យសត្រូវឈ្លានពាន !...

គ្រូពៅលាក់ឈ្មោះហៅពោធិកំបោរ ទះដៃទទួលអបអរសាទរនឹងពាក្យប្តេជ្ញារបស់ស្នាគ្របក្សពួក ៖

– អរគុណណាស់ ដែលបងប្អូនទាំងអស់បញ្ចេញការពិតប្រាកដ ដោយសន្តានចិត្តក្លាហានអង់អាចដូច្នេះ ។ សូមទេវតាទាំងទិសទសោឡសស្ថាន និងវត្ថុសក្តិសិទ្ធិទាំងអស់ក្នុងទឹកដីខ្មែរ ជួយប្រដុងប្រជាយើងឲ្យបានសំរេចតាមបំណងគ្រប់ៗគ្នា !

ក្រោយពីរៀបចំពិធីប្រក់ព្រំសព្វគ្រប់ហើយ ពោធិកំបោរបរពលឆ្ពោះទៅកាន់ខេត្តរោងដំរី ដោយសេចក្តីក្លាហានមុះមុតពេញជាកូនខ្មែរ មានសាច់ឈាមជ័រអ្នកចំបាំងមែនៗ ។ យុទ្ធជនយើងបង្ហាញចំពោះភ្នែកបរទេស នូវវីរភាពដ៏ខ្ពង់ខ្ពស់ ដែលមិនអាចកាត់តម្លៃបានឡើយ ។

ថ្វីដ្បិតតែកុលបុត្រខ្មែរមានត្រឹមដាវ លំពែងធ្នូស្នាជាអាវុធយុទ្ធោបករណ៍ តាមបែបបូរាណនិយមដូច្នេះក៏ដោយ ក៏គ្មានទឹកញញើតទាហានបារាំងដែលប្រដាប់ដោយកាំភ្លើង ទាន់សម័យដ៏តិចតួចសោះ ។ ព្រោះម្នាក់ៗសឹងតម្កល់តម្កើងជាតិសាសនានិងទឹកដីកេរ្តិ៍ពីដូនតា ឲ្យនៅខ្ពស់ជាងសិរសាខ្លួនជានិច្ច ។ បរទេសណាហ៊ានរុករានទន្ទ្រានតីស្រេចនឹងក្បាលចិត្ត ដោយកិរិយាមើលងាយវាយបន្ថោកខ្មែរ ទុកដូចប្រមាថម្តាយចង់រំលាយព្រះ ដែលជាទីសក្ការៈបូជាស្មើនឹងដួងព្រលឹង កូនខ្មែរស្នេហាមាតុភូមិដ៏មុះមុតមិនព្រមអត់ឱនឲ្យជាដាច់ខាត ។ បើជីវិតរស់នៅត្រូវតែកម្ចាត់កម្ចាយចោរឈ្លានពាន រហូតដល់វិនាសសន្តិអសេសតោរអស់ពីមាតុប្រទេស ។ បែរជាស្លាប់ក្នុងនាមអ្នកតស៊ូវិញ ឲ្យវិលមកយោងយកកំណើតកើតជាកូនខ្មែរទៀត ដើម្បីបានបំពើឧត្តមគតិការពារបូរណភាពទឹកដីបុរីនគរ រហូតអស់កល្បកប្ប ។

កម្លាំងកាយចិត្តបានបូជាជូបជាតិអស់ហើយ គ្មានអ្វីនាំឲ្យរារែកខ្លាចរអានឹងសេចក្តីស្លាប់ទេ ប្រសិនបើការចែកឋានទៅកាន់បរលោក ជាពលិកម្មដ៏ប្រសើរចំពោះប្រទេសពិតមែន ។ ប៉ុន្តែខាងខ្មែរយើងមិនងាយងាប់តែផ្តាស អាចារ្យលាក់ជាអ្នក

សិល្ប និងយល់ជើងសឹកសត្រូវប្រាកដប្រជា តើព្រមបណ្តោយឲ្យស្ទ័គ្របក្សពួកស្លាប់អាសារបង់ឬ ?

លុះគន់គួរមើលពេលជាពេលល្អហើយ គាត់ក៏បញ្ជាកងទ័ពប្រជារាស្ត្រឲ្យវាយប្រហារខ្លាំងមួយរំពេច ៖

- បងប្អូនចូល !...

យុទ្ធជនយើងរត់សំរុកតាមក្រោយពោធិកំបោរគ្មានរាថយ ព្រមជាមួយនោះសម្រែកហ៊ោយកជ័យលាន់ឮឡើងទ្រហឹងអឹងអាប់ស្ទើរក្រឡាប់ក្រឡាប្រថពី ៖

- ជយោរាស្ត្រខ្មែរស្នេហាជាតិ !!...

លេចសម្លេងដ៏ខ្លាំងក្លាប្រៀបឧបមាដូចផ្គរលាន់គំរាមមេឃ ហាក់ពញ្ញាក់ស្មារតីយោធាបារាំង ដែលមិនដឹងខ្យល់ហល់ប្រមាត់អ្វីសោះ ឲ្យភ័យស្លន់ស្លោមុចស្លេកស្លាំង រត់លូនទាំងសស្លើតសស្លក់ ទៅកញ្ឆក់យកកាំភ្លើងមក តាំងបាញ់រប៉េះរប៉ោះទំនងជាចង់បង្អើលក្រុមតស៊ូ ។

ពោធិកំបោរចេះបាលីបញ្ចៀសគ្រាប់ ប្រកបដោយប្រសិទ្ធិភាពគួរឲ្យសរសើរ គាត់គិតតែរុលទៅមុខថែមទៀត ដោយស្រែកប្រាប់កងពលនៅពីក្រោយថា ៖

- កុំភ័យបងប្អូន នាំគ្នាតាមខ្ញុំឲ្យជាប់មក៍ !...

គ្រាប់កាំភ្លើងរបស់បារាំងសាចចេញពីក្នុងបន្ទាយចំរុះចំខ្លួនអាចារ្យលាក់ម្នាក់ឯងច្រើនជាងគេ តែរកផ្តួលគាត់មិនកើតសោះឡើយ ។ សូម្បីយុទ្ធជនឯទៀត ក៏បានរួចរស់ចិវិតដោយសារឫទ្ធិចេស្តាមន្តអាគមគាថារបស់គាត់ដែរ មានត្រូវរបួសនិងស្លាប់ខ្លះ ព្រោះអ្នកទាំងនោះពុំបានកាន់ត្រណមឲ្យជិតដល់ ដូចជាភ្លាត់មាត់ជេរម្តាយកាយឪពុកគូសត្រូវជាដើម ។

ត្រង់នេះសឲ្យឃើញថា និស្ស័យរបស់ខ្មែរតាំងពីព្រេងព្រឹទ្ធមកតែងមានចិត្តបុណ្យខ្លាចបាប ប្រកាន់ខ្ជាប់នូវសីលធម៌ដើម្បីបានជាកុសលជួយប្រជុំងប្រជាក្នុងបច្ចុប្បន្ននិងទៅអនាគត ។ ខ្មែរស្គាល់បុណ្យបាបគុណទោសពិតមែនហើយ បើសាសន៍ណាហ៊ានពាធាចង់ជិះជាន់សង្កត់សង្កិនតាមទំនើងចិត្ត ខ្មែរមិនចាំបាច់ត្រូវតែដាក់សីលទុកមួយអន្លើសិន ។ ម្តងនេះ ច្បាស់ជាបានស្គាល់ទំហំទឹកចិត្តខ្មែរមិនខានហើយកុំចោទប្រកាន់ថា កូនខ្មែរលេងធម៌ក្តៅឲ្យសោះ ។

មិត្តភក្តិត្រូវបាត់បង់ជីវិតបីបួននាក់នេះ យុទ្ធជនយើងទាំងអស់ប្តូរផ្តាច់ថា ៖

- អញចាំបាច់ទាមទារបំណុលឈាមឲ្យខាងតែបាន ស្លាប់រស់មិនគិតទេ ។

លុះចូលដល់ជិតបន្ទាយហើយ ឥតបង្អង់យូរឡើយ ក្រុមអ្នកក្លាហានយើងមួយចំនួនបាញ់ផ្ទស្គាទៅវិញយ៉ាងចាស់ដៃ ។ បារាំងមិនស្គាល់ងាប់ បែរជាសើចចំអកដាក់ឲ្យខ្មែរ ព្រោះនឹកថា ៖

- គ្រាន់តែរលាត់ស្បែកប៉ុណ្ណោះ ឥតអំពើទេ...

គឺជាការភ័ន្តច្រឡំគួរឲ្យស្តាយព្រួញជ័រឆក់ដែលត្រាំថ្នាំពិសពស់គ្រប់ប្រភេទ បានគួចឆក់យកជីវិតបច្ចាមិត្រមួយគំនរគរគោក ទម្រាំទាហានបារាំងដឹងខ្លួនទាន់ គឺបានរត់ជាន់ជើងគ្នាសណ្តោងយកតែព្រះអាយុសរៀងៗខ្លួន ចោលកាំភ្លើងទីងណាត់ទីងណែងពេញបន្ទាយ ។

នៅលើប៉មប្រចាំការ បារាំងពីរនាក់បន្លឺសំរែកឡើង ដោយក្តីភ័យតក្កមាជាខ្លាំង រួចលោតទម្លាក់ខ្លួនចុះមកដួលជ្រហិតជ្រហម ល្មមពេលដែលយុទ្ធជនយើងទៅដល់ជាន់កដកស្លាបឥតអាណិត គ្មានអាសូរ...

- កុំថ្ងូរអាក្តោងវែង ស្លាប់ទៅ ! ឯងរស់នៅធ្វើអី នាំតែធ្ងន់ផែនដីអញអត់ប្រយោជន៍ !....

ខណៈដែលមនុស្សត្រចៀកស ចែកច្រកគ្នាដាក់មេជាយគ្មានដឹងទិសតំបន់ មិត្តយើងខ្លះក៏បានដៃចូលចាក់សម្លាប់សម្លេះសត្រូវ ខ្លះទៀតរើសយកកាំភ្លើងមកតាំងបាញ់ទាហានបារាំងម្តងវិញ ។

ជ័យជំនះជាគ្រាដំបូងបង្អស់នេះ អាចនឹងពង្រឹងជំហរទ័ពប្រជារាស្ត្រយើងឲ្យកាន់តែរឹងប៉ឹងថែមទៀត ព្រោះប្រមែប្រមូលយកបានគ្រឿងសញ្ជរុធ និងគ្រាប់រំសេវរបស់ខ្មាំងយ៉ាងច្រើន ។

ដើម្បីតាំងបន្ទាយ វាយមនុស្សគយល្បាតឲ្យជិតដល់គួរជាទីទំនុកទុកចិត្តថាជយភូមិ ពោធិកំបោរសំរេចវិលទៅបោះទ័ពនៅខេត្តត្បូងឃ្មុំ ។

❑ ❑

❑

## ~២~

# ឧកញ៉ាអកជូនស៊ូ

សេនាជនម្នាក់ក្នុងសំលៀកបំពាក់ឯកសណ្ឋានបំផាយអាជាសេះយ៉ាងញ័រទ្រូលោមដោយមានដំណើរឆ្ពោះទៅកាន់គេហស្ថានឧកញ៉ាអកជូនស៊ូ ដែលប្រាកដរូបរាងឡើងយ៉ាងធំស្កឹមស្កៃ ។

ឥតហ៊ានបង្អែបង្អង់ ហាក់បីដូចជាមានរឿងហេតុអ្វីធំដុំសំបើមណាស់ ទាហាននោះចងសេះត្រង់មាត់របងហើយ ក៏ម្ទីម្ទានាំខ្លួនចូលយ៉ាងរូតរះ ។

ឧកញ៉ាអកជូនស៊ូ ស្ថិតនៅក្នុងវ័យចាស់ តែកម្លាំងកំហែងនៅមាំទាំ សមតាំងពីដំណើររាជសីហ៍ ប្រកបដោយអំណាចសឹងថាជាស្ដេចត្រាញ់ ត្រួតត្រាដែនដីត្បូងឃ្មុំទាំងមូល គ្មាននរណាហ៊ានខ្វើកនឹងគាត់ទេ ។ ខណៈដែលក្រឡេកឃើញសេនាលំទោនកាយចូលមក ឧកញ៉ាអកជូនសាកសួរជាមុន ៖

- មានការណ៍អ្វីក៏ត្រហេបត្រហបខ្លាំងម្ល៉េះ ?

- ជំរាបប្រសាសន៍ព្រះតេជគុណ អាចារ្យលាក់ដែលតាំងខ្លួនជាពោធិកំបោរបានវាយបែកបន្ទាយបារាំងនៅរោងដំរីហើយ ។ ឥឡូវគេលើកទ័ពមកបោះក្នុងខេត្តយើងថែមទៀត មិនដឹងជាអាចារ្យលាក់ហ្នឹងគិតយ៉ាងណាទេ ទានប្រោស ។

- វាថ្លើមពាសមេឃ ហ៊ានតាំងខ្លួនប្រឆាំងនឹងបារាំងសែស ដែលមកជួយយកអាសារនគរយើង មិនតែប៉ុណ្ណឹងពោធិកំបោរចង់ជ្រៀតជ្រែកខេត្តខណ្ឌយើងផងអំពើទ្រើសឃ្លងបែបនេះ ពុំអាចអត់ឱនឲ្យបានទេ ។

សំដីសំដៅលាយឡំដោយហឹង្សា សឹងជំរុះចេញមកទាំងញ័រមាត់-ក ។ អកជូនស៊ូដើរក្រពាត់ដៃចុះឡើង ទ្រង់តប់ប្រមល់ទល់ពុទ្ធោ មួយសន្ទុះក្រោយមក ទើបគាត់មានពាក្យនិយាយជាមួយនឹងទាហានរក្សាស្រុក ៖

- ចូរឯងត្រឡប់ទៅធ្វើការតាមនាទីរបស់ខ្លួនចុះ !

យោធិនធ្វើគារវកិច្ចថយចេញផុត ទុកឱកាសឲ្យឧកញ៉ាអកជូនស៊ូគិតកិច្ចការផែនដីតែម្នាក់ឯង ។ គាត់សំរេចសេចក្ដីជាឯកច្ឆន្ទ ៖

- ចាំបាច់ត្រូវតែកេណ្ឌពលសកលយោធាឲ្យបានច្រើន ដើម្បីកំចាត់កំចាយស្ទ្រគបក្សពួកពោធិកំបោរ ចេញពីទឹកដីខេត្តត្បូងឃ្មុំជាដាច់ខាត ។

ប៉ុន្មានថ្ងៃនេះ មានអ្នកស្រុក-ភូមិចាប់កំណែនមិនតិចទេ ដូច្នេះកងទ័ពរក្សាខេត្តត្បូងឃ្មុំ ក៏ឃើញថាធួនល្មមនឹងចិត្តអកជូនស៊ូ ដែលបានគ្រោងទុកហើយ ។ នៅចំពោះមុខកងកម្លាំងឧកញ៉ាអកជូនបង្កក់ប្រកាសឡើង បែបខ្លាំងដៃសំបើមណាស់

- អ្នកទាំងឡាយ កុំភ័យតក់ស្លុតរន្ធត់ក្នុងចិត្តឲ្យសោះ ពិតមែនតែជាប់ក្នុងកំ- ណែន ពុំមែនបានសេចក្ដីថា យើងដឹកនាំអ្នករាល់គ្នាទៅរងគ្រោះអាសន្នអន់ក្រទេ ។ ពោលគឺយើងឈានសំដៅទៅជោគជ័យលើអាចារ្យលាក់ ដែលតាំងខ្លួនជាពោធិកំបោរ អ្នកចេះសិល្បប្រសាទលើសលែងគេឯងទាំងពួង ឲ្យវាស្លាប់តាយហោងផុតពីទឹកដី។ មនុស្សក្បត់ហ៊ានដេញបារាំងចេញពីស្រុក គឺប្រឆាំងនឹងអាជ្ញាហ្លួងពេញទីអត់ឱនមិនបានជាដាច់ខាត ត្រូវតែលើកគ្នាទៅកាប់សម្លាប់ចោលមិនចាំបាច់ជំនុំជំរះ!

ទន្ទឹមនឹងកន្ទុយពាក្យនេះ ឧកញ៉ាអកជូនធ្វើឫកមួនមាំ ដោយនិយាយខាំមាត់បត់ដុំដៃ រួចវាចាហាក់មានសង្ឃឹមញញឹមទុកក្នុងពោះជាស្រេច ៖

- ដើម្បីជាបណ្ដឹងប្ដឹងដល់ព្រះយមយក្សអារក្សអ្នកតាទេវតាទេវព្រឹក្ស ដែលរក្សាទឹកដីជ្រោះជ្រលងដងអូរគីរីបព្វតាព្រៃព្រឹក្សាគ្រប់ទិសទីក្នុងខេត្តខណ្ឌមណ្ឌលត្បូងឃ្មុំនេះ ចូរអ្នកទាំងអស់គ្នាបន្លឺសំរែកជយឃោសឡើង ជយោកងទ័ពឧកញ៉ាអកជូនស៊ូ !

ពួកពលជាប់កំណែនទាំងអំបាលម៉ាន មិនបានគិតគូរឲ្យវែងឆ្ងាយ ក៏ចេះតែសប្បាយនឹងស្រែកតាមប្រៀបដូចសារិកាកែវ ។ អកជូនស៊ូបានចិត្តក្រអឺតគាត់ដម្លើងសរសៃកបន្ថែមទៀត ៖

- បរាជ័យពោធិកំបោរ...

ប្រយោគផ្ដន្ទានេះ ពុំទាន់នឹងចប់ស្រួលបួលផង រកអ្នកស្រុកឯទៀតបន្ទរមិនទាន់ ស្រាប់តែព្យុស្ទូរកាំភ្លើងផ្ទុះឡើងបីណាត់ផ្ទួនគ្នា ជាហេតុបណ្ដាឲ្យពលរេហ៍ឧកញ៉ាអកជូនស៊ូភ័យស្លេស្លេតស្លក់ភ្នែកល្ងក់ ក្រឡេតក្រឡាប់ចាប់រកមើលគ្រប់ទិ- សទី ។ មានទាហានមួយចំនួនស្រែកភ្លាត់មាត់-ក ៖

- ពោធិកំបោរលើកទ័ពមកដល់ហើយ...

គ្រាន់តែដឹងដូច្នេះភ្លាម ខ្លះចង់រកច្រករត់យកព្រះអាយុស ខ្លះទៀតស្លុតខ្លាំងទៅជាញ័រឈរជើងស្ទើរមិនជាប់នឹងដី ។ ដើម្បីលើកកម្លាំងចិត្តកូនចៅក្រោមបង្គាប់ឧកញ៉ាអកជូនស៊ូដម្លើងសម្លេងកាន់ព្យក្រាងក្រឪ ៖

- កុំភ័យឲ្យសោះ តាំងចិត្តអង់អាចក្លាហានឡើង ចាប់អាវុធគ្រប់ដៃត្រៀមខ្លួនចាំសម្លាប់សត្រូវភ្លាម !

នៅមិនឆ្ងាយប៉ុន្មានពីទីនេះ អាចារ្យលាក់បរពលលុកយ៉ាងក្លៀវក្លា ៖

- បងប្អូនចូល ! ជ័យជំនះពិតជារង់ចាំយើងខាងមុខ !

ស្នូរសន្ធឹកជើងសឹករណ្ដំផែប្រថពីស្ទើរក្រឡាប់ ពួកពលទាំងសងខាងមីរដេរដាស ឃើញតែក្បាលសឹងកកស្រទាប់លើគ្នា ចាប់ផ្ដើមប្រគុំភ្លើងអាវុធយុទ្ធភ័ណ្ឌលាន់ព្យុទ្រហឹងអឺងអាប់គ្រប់ទិសទី ប្រៀបបាននឹងស្នូរកាំរន្ទះវះទ្រូងមេឃពុះជ្រែក

កាត់អាកាសវេហាស៍ ។

គូបដិបក្សល្បែងប្រើល្បិចកិច្ចកល ដោយរលាស់មុខដាវលំពែងជញ្ជែងហែកហូរសាច់ឈាម ដល់នូវក្តីមរណៈដួលដេកទីងណាត់ទីងណែង ត្រាំក្នុងថ្លុកលោហិតក្រហមច្រាលឆ្អៅពាសវាលពាសកាល មុខគួរឲ្យអាណោចអាធម៌ពន់ពេក ។

រីឯសំរែកលាលោក ច្របូកច្របល់នឹងចលនាអាវុធ ចេះតែលេចឮបន្តទៅទៀតស្ទើរពុំដាច់រយៈ ម្ខាងៗគិតយ៉ាងណាឲ្យតែបានប្រហារដៃគូ ដើម្បីដណ្តើមយកបានកំរងជោគជ័យជាចុងក្រោយបង្អស់ ។ តើជ័យជម្នះនឹងត្រូវធ្លាក់ទៅខាងណា ?

ការប្រយុទ្ធយកស្លាប់រស់ រវាងកងទ័ពពោធិកំបោរ និងឧកញ៉ាអកជូនស៊ូកាន់តែខ្លាំងក្លាលើសដើម ហាក់បង្ខំវាយផ្តាច់ព្រ័ត្រក្នុងរយៈពេលយ៉ាងខ្លីបំផុត ។ កងកម្លាំងប្រជារាស្រ្តយើង មានប្រៀបលើពលរេហ៍អកជូនតាំងពីដើមទីមក ក៏រឹងរឹតតែបង្ហាញឲ្យឃើញនូវថ្វីអាវុធឆើតឡើងជាលំដាប់លំដោយ ។

កាលបើយល់សេនាទាហានរបស់ខ្លួនថយដៃចូរច្រេះ អកជូនឆ្កេឆ្កាដូចមាន់រកពង គាត់មិនដឹងគិតទៅជួយខាងណាមកខាងណាទេ មានតែមាត់ស្រែកឡូឡាកំឡាចិត្តប៉ុណ្ណោះ ៖

– ទេវតារក្សាស្វេតឆ័ត្រនឹងបរាមុខពួកអាក្បត់ឯងមិនខាន !

ពាក្យស្រមើស្រមៃតែផ្តាសរបស់ឧកញ៉ាអកជូននេះ ត្រូវអាចារ្យលាក់ឆ្លើយទៅវិញ ប្រកបដោយសំនួនវោហារចាក់ចុចចំចំណុចខ្សោយ ៖

– យើងជឿជាក់ថា គ្មានទេវតាឯណាទៅរក្សាស្វេតឆ័ត្រ ដែលស្តេចទុកដាក់ខ្លួនឯងជាខ្ញុំបារាំងនោះទេ ។ ពោធិកំបោរយើងប្រឆាំងជាដាច់ខាតនឹងបរទេសឈ្លានពាន ព្រមទាំងខ្មោចក្នុងដែលឲ្យដៃវា ពោលគឺហ្លួងសព្វថ្ងៃនេះតែម្តង !

– ជើ... ពោធិកំបោរឯងហ៊ានប្រមាថកាតទានព្រះចេស្តាព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូងផង ? កំហុសដ៏ធ្ងន់នេះ ឯងត្រូវតែទទួលទោសកំបុតក !

អាចារ្យលាក់ឥតមាននឹកញញោចក្នុងចិត្តបន្តិចបន្តួចទេ គាត់រលាក់សំណើចក្អាកក្អាយដូចទឹកធ្លាក់ទំនប់ ដើម្បីចំអកឡកឡឺយឲ្យគូសន្ទនា ដែលជាអ្នកទ្រទ្រង់របបរាជានិយមសក្តិភូមិ ។

ពេលជាមួយគ្នានោះ ស្នូរកាំភ្លើងផ្ទុះឡើងមួយគ្រាប់ ត្រូវឧកញ៉ាអកជូនស៊ូរលំដួលតូង ប្រៀបដូចដើមឈើរន្ទះបាញ់រលើងឫសកែវ ជនរងគ្រោះថ្ងូចថ្ងូររហឹម ៖

– អ៊ូយ ! យើងត្រូវរបស់គេហើយ !...

ហេតុតែអាយុមិនទាន់អស់ សេនាជំនិតបួនប្រាំនាក់ បានលើកគ្នាមកជួយយកអាសារ ដោយនាំឧកញ៉ាអកជូនភៀសខ្លួនចេញចាកវឿណារុង្គកាត់ហ្វូងទាហាន ដែលបាក់ទ័ពរត់របាត់របាយគ្មានដឹងទិសតំបន់ ។

ឥឡូវនេះ កងកម្លាំងមួយចំនួនបានជូនដំណើរអកជូនស៊ូតាមផ្លូវទឹក ។ ទូកជាច្រើនលូនលឿនលយឆ្លងទន្លេ តាមមង្គលទៅបញ្ឈប់ច្រវាជើងចែវក្នុងខេត្តកំពង់សៀម ។

ទាហានដែលតាមមកជាប់ទាំងអំបាលម៉ាន នាំគ្នាខិតខំព្យាបាលមុខរបួសឧកញ៉ាអកជូន ត្រាតែជាសះស្បើយ រហូតដល់មានកម្លាំងកំហែងដូចធម្មតា ។ គាត់បានវាចាទៅកាន់កូនចៅទាំងឡាយ ដែលស្ថិតនៅចំពោះមុខ ៖

- យើងមិនត្រូវបណ្តែតបណ្តោយឲ្យពោធិកំបោរ បានចិត្តឡើងចាងតទៅទៀតទេ ដូច្នេះចាំបាច់ធ្វើសំបុត្រទៅក្រាបបង្គំទូលហ្លួង សូមទ្រង់ជ្រាបគ្រប់ប្រការ ។ បើនឹងទុកយូរទៅបណ្តារាស្ត្រខេត្តបាភ្នំ រំដួល ស្វាយទាប និងព្រៃលើ ដែលសុទ្ធសឹងតែចំណុះចុះចូលខាងពោធិកំបោរ បះឡើងកាលណា រាជការយើងប្រាកដជាពិបាកទប់ទល់ហើយ !

កាលបើបានទទួលបង្គាប់នេះ ស្មៀនស្មេរម្នាក់ពីរខិតខំតែងសេចក្តីយ៉ាងផ្ចិតផ្ចង់ ដើម្បីទៅថ្វាយស្តេចឯវាំងភ័ត (១) ក្រុងភ្នំពេញ ។

ក្រោយពីនោះមក ឧកញ៉ាអកជូនស៊ូលើកកងពលសកលយោធាត្រឡប់ទៅបោះនៅពាមមង្គល ខេត្តត្បូងឃ្មុំ ដោយចេញបញ្ជាទៅគ្រប់មេពួក-ក្រុម ៖

- នាយរាល់គ្នាត្រូវការពារបន្ទាយ រាយពលគយល្បាតឲ្យបានជិតដល់មែនទែន បើបុំនោះសោតទេប្រយ័ត្នថ្លោះធ្លោយការដុំកំភួន និងមានទោសដល់ប្រហារជីវិតបង់ !

មេ-ពួកក្រុមទាំងអស់ស្រុះស្រួលមូលមាត់ទទួល ៖

- សូមគោរពតាមប្រសាសន៍ព្រះតេជគុណជាម្ចាស់ !

ថ្ងៃនេះ សភាពស្ងប់ស្ងាត់បានគ្របដណ្តប់ផ្ទៃជំរំឧកញ៉ាអកជូននៅពាមមង្គលឲ្យធ្លាក់ទៅក្នុងតុណ្ហីភាពប្រៀបដូចដែនព្រៃស្មសានឋានស្ងាត់ ឮសូរតែមាត់សត្វយំឆ្លងឆ្លើយគ្នាយ៉ាងលន្លង់លន្លោច ។ យូរៗស្នូរត្រដោកផ្លាស់យាមបន្លឺឡើង ពុះជ្រែកលង្វែកអាកាសបែបល្វើយតាមរលកខ្យល់ ដែលបត់បញ្ជូនសម្លេងនេះ ទៅឆ្ងាយរហូតជើងមេឃឯនាយ ។

ទាហានមាននាទីជាអ្នកយាមល្បាត គ្រប់ច្រកល្ហកត្រាច់រង្កាត់ទៅមកជុំវិញបន្ទាយ ខ្លះហាក់ទុកចិត្តថា ៖

- មេឃស្រឡះល្អបែបនេះ ដូចជាគ្មានអាសន្នអន់ក្រកើតឡើងទេ ។

(១) *វាំងភ័តស្ថាបនារួចស្រេចក្នុងឆ្នាំឆ្លូវ សប្តស័កព.ស.២៤០៩ គ.ស.១៨៦៥ នៅខាងជើងវត្តឧណ្ណាលោមត្រង់រោងចក្រធ្វើទឹកកក ។ ឯវាំងចតុមុខកសាងហើយជាខាងក្រោយ ក្នុងឆ្នាំមមីទោស័ក ព.ស.២៤១៤ គ.ស.១៨៧០ ដែលសល់តំណែលរហូតដល់សព្វថ្ងៃ ។*

តើនរណាម្នាក់នឹកដល់រណភ័យ ដែលកើតឡើងដោយពុំបានឲ្យតម្រុយជាមុនសោះ ? រំពេចនោះ សំរែកហ៊ោកញ្ជៀវយកជ័យលេចឮឡើងទ្រហឹងអឺងអាប់ហាក់ក្រឡាប់ផែនប្រថពីគិរីបព្វតា ៖

- ជយោកងកម្លាំងពោធិកំបោរ !
- ទឹកដីជាកេរ្តិ៍ដូនតាខ្មែរត្រូវនៅជារបស់ខ្មែរដដែល !
- បរាជ័យបរទេសឈ្លានពាន និងបរិវារទាំងឡាយ !

ពាក្យស្លោកហូរចេញពីមាត់មិត្តទាំងអស់ សុទ្ធសឹងបញ្ជាក់ឲ្យឃើញនូវសន្តានចិត្តស្នេហាជាតិមាតុភូមិយ៉ាងប្តូរផ្តាច់ ទោះបីត្រូវបាត់បង់ជីវិតក៏ដោយ ឲ្យតែជាតិរស់មានកេរ្តិ៍ឈ្មោះល្បីរន្ទឺព្ទសុសសាយ ថាជាឯកអគ្គប្រទេស មានប្រជារាស្ត្រប្រកបដោយវីរភាពឧត្តម សក្តិសមនឹងតំណពូជពង្សវង្សត្រកូលកសាងមហាស្ថាបត្យកម្មអង្គរវត្ត ទុកជាសក្ខីភាពនៃរុងរោចន៍ត្រចះត្រចង់ បីដូចច័ន្ទថ្លានាថ្ងៃពេញបូណ៌មី ។

ព្វដ៏កាលណោះ យុទ្ធជនយើងជម្រុញជំហានទៅមុខជាដរាបគ្មានរារែក ឯខាងពលខាងឧកញ៉ាអកជូនស៊ូនៅរង់ចាំទទួលរណាយុទ្ធទាំងស្ទាក់ស្ទើរក្នុងចិត្ត ត្បិតឃើញក្រុមអ្នកតស៊ូប្រដាប់ដោយគ្រឿងអាវុធ សង្វើញចូលលុកតាមក្បួនយុទ្ធសាស្ត្រយ៉ាងជំនាញ ។

ចាប់គូតស៊ូយកស្លាប់រស់មួយរំពេច នរណាភ្លេចភ្លាំងភ្លេងអាវុធ ច្រឡំក្បាច់ភ្លាត់ស្នៀត ច្បាស់ជាអ្នកម្ខាងទៀតឆ្លៀតយកឱកាសល្អហុចឲ្យចាក់សម្លាប់ កាប់សម្លេះដៃគូ ត្រាតែងាប់តែហោងរដូករណែល ក្នុងថ្លុកឈាមឆ្អានខ្នុរខ្មោះ ។ ទ្រាំពុំបានពួកពលខាងឧកញ៉ាអកជូនមួយចំនួនរត់ប្រាសចោលទីប្រយុទ្ធ សណ្តោងរយោងយកតែព្រះអាយុសទៅជួបមុខប្រពន្ធកូន ។

យល់ប្រច័ក្ខដូច្នេះ អកជូនស៊ូក្តៅក្រហល់ក្រហាយក្នុងចិត្តឥតឧបមា គាត់ស្រែកជេរប្រទេចផ្តាសាតាមកំហឹងឆេះឆួល ស្រាប់តែគ្រាប់កាំភ្លើងហើរមកទម្លុះទ្រូងបាត់មាត់ដូចគេចុកមួយរំពេច ។ លោហិតខ្ពុរចេញភលៗជាបខ្លួនប្រាណ ទ្រេតទ្រោតឈរត្រដរខ្យល់បានប្រហែលមួយដង្ហើមដែរ ទម្រាំតែឧកញ៉ាអកជូនដួលដេកស្លាប់យ៉ាងសោះកក្រោះ ។

លុះឃើញចៅហ្វាយនាយចែកឋានទៅហើយ កូនចៅក្រោមបង្គាប់ទាំងអំបាលម៉ាន ទ្រាំទ្រនៅរឹងទទឹងមុខសឹកលែងកើត ក៏នាំគ្នាចែកច្រកដាក់មេផាយខ្ចាត់ខ្ចាយអស់រលីង ។ នរណាដោលខ្លួនទៅមិនទាន់គេ ព្រោះមានរបួសបាក់ដៃជើង បែកក្បាលក្បុងស្រែករលូងអាកាស វិស័យប្រេតនរកអវិចីភ័យស្លន់ស្លោខ្លាចទណ្ឌកម្ម

- ពុទ្ធោ... ព្រះអើយជួយខ្ញុំផង !...

មានខ្លះខំត្រដររត់លូន ទាល់តែដាច់ខ្យល់ស្លាប់តាយហោងមុខគួរឲ្យសង្វេគ ។

កម្រងជោគជ័យបានធ្លាក់ មកលើមិត្តយុទ្ធជនយើង ដែលធ្វើការតស៊ូពុះពារគ្មានខ្លាចនឿយហត់ ពោលគឺសុខចិត្តធ្វើពលិកម្មគ្រប់បែបយ៉ាង ដើម្បីជាតិ សាសនា និងមាតុភូមិខ្មែរ ដែលខេមរកុលបុត្រកុលធិតាដម្កល់ដម្កើងទុកស្មើនឹងជីវិតិន្ទ្រីយ៍។

ដើម្បីពង្រីកពង្រឹងកងកម្លាំងឲ្យខ្លាំងពូកែមានស្មេរភាពតរៀងទៅ គ្រូពៅលាក់ឈ្មោះហៅពោធិកំបោរបានបោះទ័ពនៅបង្ហាត់ហ្វឹកហ្វឺនរេហ៍ពលឲ្យជំនាញជាយជ័យក្នុងទឹកដីពាមមង្គល ។

❑ ❑

❑